Nº 3

# បម្រាមចំពោះគណបក្សនយោបាយ
# បេក្ខជន និងតំណាងគណបក្សនយោបាយ

**សំណួរ:** **តើសកម្មភាពអ្វីខ្លះ ដែលគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវធ្វើក្នុងដំណាក់កាលឃោសនាបោះឆ្នោត និងបោះឆ្នោត ?**

**ចម្លើយ:** -ក្នុងដំណាក់កាលឃោសនាបោះឆ្នោត និងបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវអនុវត្តដូចខាងក្រោម ÷

-ប្រើកម្លាំង អំពើហិង្សា ឬបំភិតបំភ័យដល់អ្នកបោះឆ្នោត ឬរារាំងអ្នកមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។

- ញុះញង់ឱ្យអ្នកគាំទ្រ ឬ អ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាម កំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

-រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់របស់ គ.ជ.ប ។

- ប្រើកម្លាំង ឬអំពើហិង្សា បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

-បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោត និងការងាររាប់សន្លឹកឆ្នោត មិនអាចប្រព្រឹត្តទៅបាន ។

-ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

-ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោត ដែលមានសន្លឹកឆ្នោត ។

- ទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត បន្ថែមលើតំណាងគណបក្សនយោបាយ ដែលអនុញ្ញាតជាផ្លូវការរួចហើយ ។

- ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោតឡើយ ។

- ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ម៉ាស៊ីនថតសម្លេង ទូរស័ព្ទថតរូប ឬឧបករណ៍ណាដែលអាចថតរូបបានផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

- នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

**សំណួរ:** **តើនៅមានប្រការអ្វីខ្លះទៀតដែលគណបក្សនយោបាយ បេក្ខជន និង តំណាងគណបក្សនយោបាយ ត្រូវជៀសវាង ?**

**ចម្លើយ:** នៅមានប្រការមួយចំនួនទៀតដែលគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ត្រូវចៀសវាងដូចជា ÷

-មិនត្រូវរារាំង រំខាន ឬបង្កើតពាក្យចចាមអារាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្សនយោបាយ ឬ បេក្ខជនដទៃទៀតឡើយ ។

-មិនត្រូវប្រើប្រាស់នូវភាសា ពាក្យសំដីដែលស្តែងចេញពីការសេពសុរា ឬ គ្រឿងញៀនដែលជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំបំភិតបំភ័យណាមួយឡើយ ។

-មិនត្រូវយល់ព្រមឱ្យដាក់តាំង ឬបង្ហាញ ឬចែកចាយ ការពិពណ៌នាអំពីការវាយប្រហារ ឬអាវុធនោះឡើយ ។

-មិនត្រូវផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតទេ ហើយថែមទាំងគ្មានសិទ្ធិជ្រៀតជ្រែក ដល់ដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀតដែល ទាក់ទងនឹងការងារបោះឆ្នោតឡើយ ។

**សំណួរ:** **ក្នុងដំណាក់កាលឃោសនាបោះឆ្នោត តើគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ត្រូវមានអាកប្បកិរិយាបែបណាចំពោះអ្នកបោះឆ្នោត ?**

**ចម្លើយ:** ក្នុងដំណាក់កាលឃោសនាបោះឆ្នោត គណបក្សនយោបាយ បេក្ខជន ឬតំណាងគណបក្សនយោបាយ មិនត្រូវធ្វើការគាបសង្កត់ ឬគំរាមកំហែង និងគ្មានសិទ្ធិបង្ខិតបង្ខំអ្នកមានសិទ្ធិបោះឆ្នោតឱ្យធ្វើសម្បថ ដោយសន្យាថា បោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួនឡើយ ។

មិនតែប៉ុណ្ណោះគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវផ្តល់សម្ភារៈ ឬប្រាក់កាស ឬផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើក ទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ទោះបីតាមមធ្យោបាយណាមួយក៏ដោយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត រហូតដល់ថ្ងៃបោះឆ្នោត ។ ហើយថែមទាំងមិនត្រូវបង្គាប់បញ្ជា ឬលួងលោម បោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយ តាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោតឡើយ ។

**សំណួរ:** **ក្នុងដំណាក់កាលឃោសនាបោះឆ្នោត តើគណបក្សនយោបាយ និងបេក្ខជនត្រូវគោរពតាមអ្វីខ្លះ ?**

**ចម្លើយ:** ក្នុងដំណាក់កាលឃោសនាបោះឆ្នោត គណបក្សនយោបាយ និងបេក្ខជនត្រូវគោរព ÷

-គោលការណ៍នៃការឃោសនាបោះឆ្នោត ដែលមានរយៈពេល ៣០ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោត ត្រូវបញ្ឈប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត ។ គ្រប់សកម្មភាពនៃការឃោសនារបស់គណបក្សនយោបាយ និង បេក្ខជន ត្រូវឈប់សម្រាកចន្លោះពីម៉ោង ១០យប់ ដល់ ម៉ោង ៦ព្រឹក។ ឯសកម្មភាពឃោសនាដោយឧបករណ៍បំពងសម្លេងត្រូវហាមឃាត់ចាប់ពីម៉ោង ១២ថ្ងៃត្រង់ ដល់ម៉ោង ២រសៀល ។

- ត្រូវគោរពបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង ច.ប.ត.រ បទបញ្ជា និងនីតិវិធី គ.ជ.ប ក្រមសីលធម៌ និងគោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**សំណួរ:** **ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយរបស់ខ្លួន តើគណបក្សនយោបាយ និងបេក្ខជន គប្បីធ្វើដូចម្តេចខ្លះ ?**

**ចម្លើយ:** ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គ្រប់គណបក្សនយោបាយ និងបេក្ខជន មិនត្រូវប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ឬធ្វើឱ្យច្របូកច្របល់ បាត់ទំនុកលើការសម្ងាត់នៃការបោះឆ្នោតទេ ។

**សំណួរ:** **ក្នុងការចាក់ផ្សាយព័ត៌មានរបស់ខ្លួនក្តី ការឃោសនារកសម្លេងឆ្នោតក្តី តើគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយគប្បីធ្វើយ៉ាងដូចម្តេច ?**

**ចម្លើយ:** -គណបក្សនយោបាយ និងបេក្ខជន មិនត្រូវចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសម្លេងតាមផ្លូវសាធារណៈណាមួយដែលមានសម្លេងខ្លាំងៗលុបលើសម្លេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀតឡើយ ។

- គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ និងអ្នកគាំទ្រ មិនត្រូវប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ឬព្រះនាមព្រះមហាក្សត្រ ព្រះនាមព្រះមហាវីរក្សត្រ ឬស្លាកសញ្ញា គ.ជ.ប ដើម្បីឃោសនារកសម្លេងឆ្នោតឡើយ ។

**សំណួរ:** **តើគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ត្រូវគោរពគោលការណ៍ផលិត និងការបិទផ្សាយឯកសារឃោសនារកសម្លេងឆ្នោតបែបណាខ្លះ?**

**ចម្លើយ:** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវ ÷

-ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃ មកប្រើប្រាស់បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន ។

- បិទប័ណ្ណ ខិត្តប័ណ្ណ រូបភាពឃោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសាឃោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃឡើយ ។

- បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវប័ណ្ណបិទផ្សាយ ខិត្តប័ណ្ណ សេចក្តីប្រកាសនយោបាយ ឬ ឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ស្ថាប័ននានា ឬអាជ្ញាធរដែនដីឡើយ ។

- បិទប័ណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាស នយោបាយ ចងបដា ឬឯកសារឃោសនាដទៃទៀតក្បែរការិយាល័យបោះឆ្នោត ក្នុងចម្ងាយតិចជាង ១០០ម៉ែត្រ និងមិនត្រូវចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈឡើយ ។

**សំណួរៈ** **តើគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ អាចប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរដ្ឋ ដើម្បីបម្រើសកម្មភាពឃោសនាបោះឆ្នោត ឬដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោតបានដែរ ឬទេ ?**

**ចម្លើយៈ** គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ មិនត្រូវប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរដ្ឋដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ផ្លាកសញ្ញារាជការ ឬរដ្ឋ ន.ប ខ.ម និងរាជរដ្ឋាភិបាល ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

**សំណួរៈ** **ការប្រើប្រាស់ឥទ្ធិពល ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ តើគណបក្សនយោបាយ បេក្ខជន ឬតំណាងគណបក្សនយោបាយអាចធ្វើទៅបានដែរ ឬទេ ?**

**ចម្លើយៈ** គណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់ មិនត្រូវប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិឥទ្ធិពល ឬសិទ្ធិអំណាចខាងចៅហ្វាយនាយ ខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទំលាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបាននូវការគាំទ្របានទេ ។

**សំណួរ:** **ក្នុងករណីដែលសង្កេតឃើញថា តំណាងគណបក្សនយោបាយមានចេតនារារាំង ឬបង្កឧបសគ្គដល់ការបំពេញភារកិច្ចរៀបចំការបោះឆ្នោត តើប្រធានការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោត មានសិទ្ធិចាត់ការយ៉ាងដូចម្ដេចខ្លះ ?**

**ចម្លើយ:** ដោយពុំទាន់គិតដល់ទោសប្បញ្ញត្តិ ដូចមានចែងក្នុង ច.ប.ត.រ ប្រធានការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត ឬប្រធាន គឃ/សប មានសិទ្ធិបណ្ដេញចេញពីការិយាល័យ ចំពោះតំណាងគណបក្សនយោបាយណាដែលមានចេតនារារាំង ឬ បង្កឧបសគ្គដល់ការបំពេញភារកិច្ចរៀបចំការបោះឆ្នោត ។